## ១. តើមូលនិធិដំឡើងស្នាដៃថ្មីមានប្រតិបត្តិការដូចម្ដេចខ្លះ?

សម្រាប់ឆ្នាំ២០២៥នេះ មូលនិធិដំឡើងស្នាដៃថ្មី នៅតែរក្សារចនាសម្ព័នជា ៣ស្រទាប់ដដែលមានដូចជា៖

- មូលនិធិទី១៖ «មូលនិធិសម្រាប់អនុវត្តគម្រោង» ថវិកាចំនួន ៣០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិយកទៅអនុវត្តដំណើរការនៃការដំឡើងស្នាដៃ
- មូលនិធិទី២៖ «មូលនិធិសម្រាប់អ្នកប្រឹក្សាផ្នែកសិល្បៈ» ថវិកាចំនួន ១០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិធ្វើការជាមួយអ្នកប្រឹក្សាផ្នែកសិល្បៈ
- មូលនិធិទី៣៖ «មូលនិធិសម្រាប់ការធ្វើបទបង្ហាញ» ថវិកាចំនួន ១០០០ដុល្លារអាមេរិក សម្រាប់ឱ្យអ្នកទទួលមូលនិធិយកទៅប្រើប្រាស់ដើម្បីដាក់បង្ហាញស្នាដៃនៅពេលបញ្ចប់

## ២. តើគោលដៅរបស់មូលនិធិមានអ្វីខ្លះ?

មូលនិធិដំឡើងស្នាដៃថ្មីត្រូវបានបង្កើតឡើងដើម្បីគាំទ្រទៅលើស្នាដៃថ្មីនៃទម្រង់សិល្បទស្សនីយភាពនានា។ មូលនិធិនេះលើកទឹកចិត្តឱ្យសិល្បករ សហគមន៍សិល្បៈ បង្កើតភាពច្នៃប្រតិដ្ឋតាមរយៈការបង្កើតស្នាដៃថ្មី ឬស្នាដៃមានស្រាប់ត្រូវការអភិវឌ្ឍបន្ថែម។ លើសពីនោះទៀតមូលនិធិនេះ ក៏បានជួយបង្កើតជាវេទិកាមួយសម្រាប់សិល្បករធ្វើការចែករំលែក និងឆ្លុះបញ្ចាំងអំពីរឿងរ៉ាវសង្គមកម្ពុជានាពេលបច្ចុប្បន្នតាមរយៈការបង្ហាញ ស្នាដៃថ្មីរបស់ខ្លួន។

## ៣. តើអត្ថប្រយោជន៍នៃមូលនិធិនេះមានអ្វីខ្លះ?

សិល្បករនឹងទទួលបានការឧបត្ថម្ភជាមូលនិធិសរុបចំនួន **៥០០០** ដុល្លាអាមេរិក។ លើសពីការទទួលបានការឧបត្ថមសិល្បករនឹងទទួល បានការបណ្តុះបណ្តាលមូលដ្ឋាននៃការគ្រប់គ្រង និងដឹកនាំគម្រោងដែលផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ។ សិល្បករនឹងបានស្វែង យល់ពីរបៀបនៃការធ្វើការងារជាក្រុម ការគ្រប់គ្រងពេលវេលា និងការបែកចែកតួនាទីនៅក្នុងដំណើរនៃការដំឡើងស្នាដៃផងដែរ។ មូលនិធិសម្រាប់អ្នកប្រឹក្សាផ្នែកសិល្បៈក៏នឹងជួយបង្ហាញផ្លូវដល់សិល្បករក្នុងការផ្ចិតផ្ចង់គំនិតសិល្បៈរបស់ខ្លួនទៅក្នុងស្នាដៃនេះដែរ។

## ៤. តើនរណាជាអ្នកចូលរួមគោលដៅសម្រាប់មូលនិធិនេះ?

- សិល្បករវ័យក្មេង ឬជាសិល្បករមានពិសោធន៍ច្រើនគួរសម ហើយមានការតាំងចិត្តខ្ពស់ចំពោះអាជីពរបស់ខ្លួន
- សិល្បករដែលធ្វើការក្នុងទម្រង់ទស្សនីយភាព (មានដូចជា ល្ខោន របាំ តន្ត្រី) ឬជាសិល្បករដែលធ្វើការលើពហុទម្រង់ តែត្រូវតែយកទម្រង់ទស្សនីយភាពជាគោល ឧទាហរណ៍ ល្ខោន និង សិល្បៈបង្គុំ, តន្ត្រី និង គំនូរ, របាំ និង កុន ។ល។
- សិល្បករឯកត្តបុគ្គល ក្រុមសិល្បករ ឬសិល្បៈសហគមន៍

**បញ្ជាក់៖** អាទិភាពចំបងនឹងផ្តល់ទៅកាន់បេក្ខភាពស្ត្រីចំនួន **២កន្លែង**

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់មូលនិធិនេះមានអ្វីខ្លះ?

ដើម្បីអាចដាក់ពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មីបាន បេជនក្ខជនត្រូវតែគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ស្នាដៃដែលគ្រោងបង្កើតថ្មី ឬក៏ជាស្នាដៃបង្កើតថ្មីដែលមានស្រាប់ ត្រូវការអភិវឌ្ឍបន្ថែម
- បេក្ខជនអាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬជាក្រុម តែក្រុមនោះត្រូវមានសមាជិកមិនលើសពី ៨នាក់ ឡើយ (ចំពោះការដាក់ពាក្យស្នើសុំលក្ខណៈជាក្រុមសូមដាក់តែឈ្មោះអ្នកតំណាងក្រុមម្នាក់គត់)
- ស្នាដៃត្រូវមានរយៈពេលសម្តែងយ៉ាងតិច ៣០នាទី និងមិនលើសពី ៤៥នាទី
- បេក្ខជនកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជាអំឡុងពេលនៃការអនុវត្តគម្រោង និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬទិដ្ឋាការ K-Visa
- ពាក្យស្នើសុំត្រូវតែជាពាក្យស្នើសុំដែលចេញដោយអង្គការសិល្បៈខ្មែរអមតៈតែប៉ុណ្ណោះ
- បេក្ខជនអាចសរសេរពាក្យស្នើសុំដោយដៃ ឬដោយកុំព្យូទ័រ ជាភាសាខ្មែរ ឬអង់គ្លេស។ ម៉្យាងវិញទៀតបេក្ខជនក៏អាចថតចម្លើយ ជាវីដេអូ ឬជាសំឡេងក៏បាន។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ បេក្ខជនអាចទាក់ទងតាមរយៈលេខទូរស័ព្ទ ០៧៧ ៧៩៣ ៥៣៧ / ០១០ ៤៨៣ ៩៤៧
- ពាក្យស្នើសុំអាចផ្ញើមកតាមរយៈអ៊ីម៉ែល samath@cambodianlivingarts.org ឬអាចយកមកដាក់ផ្ទាល់នៅការិយាល័យ អង្គការសិល្បៈខ្មែរអមតៈ ដែលមានអាស័យដ្ឋាននៅ ផ្ទះលេខ១១៣E ផ្លូវលេខ ៨៣០ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
- បេក្ខជនចាំបាច់ត្រូវតែពន្យល់ពីមូលហេតុ ក្នុងការជ្រើសរើសយកអ្នកប្រឹក្សាផ្នែកសិល្បៈមកជួយនៅក្នុងគម្រោងរបស់ខ្លួនដូចជា៖
  - ប្រវត្តិរូបសង្ខេបរបស់អ្នកប្រឹក្សា
  - ភាពស៊ីគ្នានៃជំនាញរបស់អ្នកប្រឹក្សាទៅនឹងគម្រោងមូលនិធិ
  - ទំនាក់ទំនងរបស់អ្នកនិងអ្នកប្រឹក្សា
  - អ្នកចង់បានការគាំទ្របែបណាពីអ្នកប្រឹក្សាសិល្បៈ
- ពាក្យស្នើសុំរបស់បេក្ខនត្រូវភ្ជាប់មកជាមួយនូវលិខិតគាំទ្រពីស្ថាប័នដែលខ្លួនកំពុងបំពេញការងារ

**ការតាំងចិត្ត៖**

- បេក្ខជនត្រូវមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងមូលនិធិនេះឱ្យសម្រេចបានជោគជ័យ
- បេក្ខជនត្រូវបង្ហាញពីជីវប្រវត្តិនៅក្នុងទម្រង់ទស្សនីយភាព ចំណាប់អារម្មណ៍ ឆន្ទៈ ចក្ខុវិស័យ និងត្រូវបង្ហាញពីគម្រោងបង្កើត ស្នាដៃថ្មីរបស់ខ្លួន
- បេក្ខជនត្រូវបង្ហាញពីការតាំងចិត្តទៅលើការបំពេញរបាយណ៍ (ភាសាខ្មែរ ឬ អង់គ្លេស) ដោយគម្រូរបាយការណ៍នឹងផ្តល់ជូន ដោយក្រុមការងារសិល្បៈខ្មែរអមតៈ។ របាយណ៍ទាំងនេះត្រូវបញ្ចប់ឱ្យបានយ៉ាងយូរ **១ខែ** បន្ទាប់ពីគម្រោងរបស់អ្នកដំឡើង និងដាក់បង្ហាញរួចរាល់។

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់មូលនិធិនេះមានអ្វីខ្លះ?

- នៅពេលលោកអ្នកផ្ញើពាក្យស្នើសុំមកកាន់អ្នកសម្របសម្រួល គាត់នឹងបញ្ជាក់ប្រាប់អ្នកវិញ ប្រសិនបើគាត់បានទទួលពាក្យស្នើសុំរបស់អ្នក
- ប្រសិនបើលោកអ្នកមិនបានទទួលដំណឹងពីអ្នកសម្របសម្រួលក្នុងអំឡុងពេល ៣ថ្ងៃ នៃថ្ងៃធ្វើការនោះទេ សូមទាក់ទងមកអ្នកសម្របសម្រួលម្តងទៀត
- បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលពាក្យ អ្នកសម្របសម្រួលនឹងធ្វើការពិនិត្យមើលពាក្យស្នើសុំភ្លាមៗ
- ពាក្យស្នើសុំទាំងអស់ ដែលត្រឹមត្រូវតាមលក្ខខណ្ឌនឹងត្រូវបានពិនិត្យម្តងទៀតដោយយោងទៅតាមលក្ខខណ្ឌ នៃការជ្រើសរើសដែលបានកំណត់ខាងលើ
    - ការពិនិត្យមើលនេះនឹងត្រូវបានធ្វើឡើងដោយគណៈកម្មការជ្រើសរើសឯករាជ្យ
    - ប្រព័ន្ធផ្តល់ពិន្ទុនឹងត្រូវបានប្រើដើម្បីឱ្យការផ្ទៀងផ្ទាត់ពាក្យស្នើសុំមានភាពត្រឹមត្រូវ និងតម្លាភាព
- បេក្ខជនដែលជាប់ដំណាក់កាលបន្ទាប់ នឹងត្រូវបានអញ្ជើញមកធ្វើសម្ភាសន៍ នៅទីតាំងការិយាល័យអង្គការសិល្បៈខ្មែរអមតៈ ឬតាមរយៈអនឡាញហ្សូម
    - **ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៥**
- បេក្ខជនដែលបានជ្រើសរើស អ្នកសម្របសម្រួលនឹងជម្រាបដំណឹងជូននៅ
    - **ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៥**
- បេក្ខជនទាំងអស់ នឹងត្រូវបានជម្រាបជូនអំពីលទ្ធផលជ្រើសរើសនៅ
    - **ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥**

## ៧. តើគ្រោងនិងពេលរបស់មូលនិធិគឺជាអ្វី?

- គ្រោងនិងពេលរបស់មូលនិធិ គឺការការបរិច្ឆេទពេលវេលាគម្រោងនឹងត្រូវធ្វើនៅចន្លោះ **ខែឧសភា ដល់ ខែធ្នូ ឆ្នាំ២០២៥**

**បញ្ជាក់៖** អ្នកទទួលបានមូលនិធិត្រូវតែបង្ហាញអំពីគម្រោងការណ៍ នៃការអនុវត្តគម្រោងដំឡើងស្នាដៃឱ្យបានច្បាស់លាស់នៅក្នុងពាក្យស្នើសុំ (រយៈពេលនៃការអនុវត្តគម្រោងយ៉ាងតិចបំផុតរយៈពេល **៣ខែ**)

## ៨. តើនរណាជាអ្នកសម្របសម្រួល និងក្រុមការងារពាក់ព័ន្ធ?

- គណៈកម្មការឯករាជ្យចំនួន៣រូបនឹងដាក់ពិន្ទុជ្រើសរើសបេក្ខជនយ៉ាងសុក្រិត្យនិងតម្លាភាព
- មូលនិធិនេះនឹងសម្របសម្រួលដោយក្រុមការងារអង្គការសិល្បៈអមតៈ លោក ថា សំអាត ដែលមានលេខទូរសព្ទ័ ០៧៧ ៧៩ ៣៥ ៣៧ / ០១០ ៤៨ ៣៩ ៤៧ និង អ៊ីម៉េល samath@cambodianlivingarts.org

## ៩. កាលបរិច្ឆេទសំខាន់ៗ

| កាលបរិច្ឆេទ | ម៉ោង | សកម្មភាព |
|---|---|---|
| ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៥ | ៣:០០នាទីរសៀល | ប្រកាសជ្រើសរើសអ្នកទទួលមូលនិធិដំឡើងស្នាដៃថ្មី |
| ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ | ៥:៣០ - ៧:០០នាទីល្ងាច | វគ្គសំណួរនិងចម្លើយតាមហ្សូម |
| ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ | ៥:០០នាទីល្ងាច | ផុតកំណត់ទទួលពាក្យ |
| ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៥ | ជូនដំណឹងតាមក្រោយ | សម្ភាសន៍បេក្ខជនដែលជាប់វគ្គជម្រុះ |
| ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ | ៥:០០នាទីល្ងាច | ប្រកាសជ័យលាភីអ្នកទទួលមូលនិធិដំឡើងស្នាដៃថ្មី |
| ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ | ជូនដំណឹងតាមក្រោយ | អ្នកសម្របសម្រួលមូលនិធិជួបជាមួយអ្នកទទួលបានមូលនិធិទាំង៤ ដើម្បីនែនាំខ្លួននិងប្រាប់ពីដំណើរការលំអិតនៃមូលនិធិ ណែនាំពន្យល់ ពីឯកសារចាំបាច់ដែលត្រូវការដូចជា៖ កិច្ចព្រមព្រៀង របាយការណ៍ហិរញ្ញវត្ថុ ពាក្យស្នើសុំពន្យាពេល និងឯកសារតាមដាននិងវាយតម្លៃ ដំណើរការណ៍នៃការដំឡើងស្នាដៃនេះ |
| ខែមិថុនា ឆ្នាំ២០២៥ | ជូនដំណឹងតាមក្រោយ | សិក្ខាសាលាបណ្តុះបណ្តាលអំពីមូលដ្ឋាគ្រឹះនៃការគ្រប់គ្រងនិងដឹកនាំគម្រោងទៅបេក្ខជនទាំងអស់ |
| ខែឧសភា - វិច្ឆិកា ឆ្នាំ២០២៥ | ជូនដំណឹងតាមក្រោយ | ការចុះត្រួតនិងគាំទ្រដល់ដំណើរការនៃការដំឡើងស្នាដៃ (ក្រុមការងារនឹងបញ្ជាក់ពេលក្រោយ) |
| ខែធ្នូ ឆ្នាំ២០២៥ | | បញ្ចប់ដំណើរការដំឡើងស្នាដៃ |